# ចៅហ្វាយរងខេត្តព្រះវិហារគេចមុខពេលសំណួរអ្នកភូមិព្រៃឡង់សង្គ្រុបខ្លាំង

ពុធ 01 មិថុនា 2011 8:43 AM | មាស មុន្នី

នៅក្នុងវេទិកាសាធារណៈដែលរៀបចំដោយមជ្ឈមណ្ឌលសិទ្ធិមនុស្ស កម្ពុជាកាលពីម្សិលមិញអ្នកភូមិមកពីតំបន់ព្រៃឡង់បានសួរយ៉ាង សន្ធាប់ទៅលើចៅហ្វាយរងខេត្តព្រះវិហារជុំវិញភាពមហន្តរាយរបស់ព្រៃឡង់បន្ទាប់ពីរដ្ឋាភិបាលបានផ្តល់ដីសម្បទានសេដ្ឋកិច្ចនៅតំបន់ នោះទៅឲ្យក្រុមហ៊ុនឯកជន។ ប៉ុន្តែការឆ្លើយតបមិនចំគោលដៅ ក្រោយមកតំណាងខេត្តពីបក្សប្រជាជនរូបនេះក៏បានដើរចេញពីកម្មវិធី។



ដើមឈើដែលត្រូវកាប់ពីតំបន់ព្រៃឡង់

លោកស្រី ខូយ ប៊ុនថាន ចៅហ្វាយរងខេត្តព្រះវិហារ និងជាសមាជិកម្នាក់មកពីគណបក្សប្រជាជនកម្ពុជាដែលគ្រប់គ្រងអំណាច បានដើរចេញពីវេទិកាពេលដែលអ្នកសម្របសម្រួលកម្មវិធីបានព្យាយាមម្តងហើយម្តងទៀតសុំកុំឲ្យលោកស្រីនិយាយចាកប្រធាន។

អ្នកភូមិម្នាក់មកពីស្រុកជ័យសែនបានថ្លែងថា «ខ្ញុំមិនសប្បាយចិត្តឡើយ ពីព្រោះលោកស្រី ប៊ុនថាន មិនបាននិយាយផ្តោតលើចំណុចដែលប្រជាជនចង់ដឹងទេ»។

លោក ឈឹម សារុធ អ្នករៀបចំកម្មវិធីនេះពីមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាបានថ្លែងថា ក្រុមអ្នកភូមិពីតំបន់ព្រៃឡង់ប្រមាណ៣០០នាក់បាននាំសមាជិកសភា និងក្រុមមន្ត្រីមកពីគណបក្សនយោបាយទាំង៥មកជួបជុំគ្នានៅស្រុក រវៀងដើម្បីឆ្លើយនឹងសំនួររបស់អ្នកភូមិដែលបារម្ភថា គោលនយោបាយសម្បទានដីធ្លីរបស់រដ្ឋាភិបាលកំពុងតែធ្វើឲ្យប៉ះពាល់ព្រៃ ឈើធំជាងគេបំផុតរបស់ប្រទេសនេះ និងជីវភាពរបស់ពួកគាត់។

ប្រជាពលរដ្ឋចំនួន៤ខេត្ត មានខេត្តកំពង់ធំ, ព្រះវិហារ, ស្ទឹងត្រែង និងក្រចេះដែលមានភូមិកជាប់ព្រៃឡង់ ហើយដែលជីវភាពរបស់ពួកគាត់អាស្រ័យលើអនុផលដែលប្រមូលបានពីព្រៃឡង់ ជាព្រៃធំ

ជាងគេនៅកម្ពុជាទំហំ៣៦០០គីឡូម៉ែត្រក្រឡាបានទាមទារយ៉ាង ទទូចឲ្យរដ្ឋាភិបាលលុបចោលអាជ្ញាប័ណ្ណដីសម្បទាននៅព្រៃឡង់។ ហើយកាលពីថ្ងៃចន្ទដើមសប្ដាហ៍នេះ ក្រុមអ្នកតំណាងរាស្ត្រពីបក្សប្រឆាំងក៏បានដាក់ការជំរុញឲ្យ រដ្ឋាភិបាលពិចារណានិងលុបចោលសិទ្ធិទទួលបានដីពីក្រុមហ៊ុនទាំងនោះ ផងដែរ៕